ធនាគារជាតិនៃ កម្ពុជា

ប័ណ្ណប្រកាស

ធនបត្រអនុស្សាវរីយ៍ ប្រភេទ ១៥000 រៀល

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
* * * * * * * * * * *

ផ្នែកខាងមុខ



ផ្នែកខាងខួច



១. *រូបបណ្តុះជាព្រះធាយាល័ក្ខណ៍ព្រះករុណា ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា អាចឆ្លុះឃើញច្បាស់លើផ្ទៃទាំងសង្ខាង*

២. *រូបបណ្តុះអម ក្នុងទម្រង់ក្បាច់ដកចន្ទន៍ក្វាយ ដែលសមាមាត្រនៃកំរិតពន្លឺមានវិសមភាពខ្លាំងរវាងផ្នែកដែលក្វឺនិងផ្នែកមិនសូវក្វឺ*

៣. *ជាតុផ្សំសុវត្ថិភាព ជាសរសៃខ្មារៗ មានពណ៌ក្រហមនិងខៀវ រាយបង្គប់លើផ្ទៃទាំងសង្ខាងនៃក្រដាស*

៤. *ជាតុផ្សំសុវត្ថិភាព ជាសរសៃខ្មារៗមានិសិស្សមាន មានចំណាំងពន្លឺក្រោមរស្មីពណ៌ស្វាយចេញជាពណ៌ខៀវនិងពណ៌លឿងលើផ្ទៃទាំងសង្ខាង*

៥. *បង្ហិចថ្នាររាងចតុកោណស្មើបញ្ឈរកែង មានគែមមូលត្រួតពីលើក្រដាសព័ទ្ធជុំវិញនៅផ្នែកខាងមុខនៃធនប័ត្រ ។ បើពិនិត្យមើលនិងស្ទាបលើបង្ហិចថ្នានោះ ឃើញមានសាតខុសគ្នារវាងក្រដាសនិងប៉ូលីមើរ ព្រមទាំងភាពខុសគ្នាត្រង់ចំណុចត្រួតគ្នារវាងក្រដាសនិងប៉ូលីមើរនោះ*

៦. *រូបភាពបង្ហិចថ្នារាងចតុកោណស្មើ មើលពីផ្នែកខាងខ្នងនៃធនប័ត្រ*

៧. *ក្បាច់លំអបោះពុម្ពដោយទឹកខ្មៅប្រែពណ៌ ពេលកាន់ក្រដាសប្រាក់ផ្ទៀងផ្ដងចុះឡើងនឹងមានបម្រែបម្រួលរវាងពណ៌មាសនិងពណ៌ប្រាក់ និងមានលេខ "១៥០០០" ពីរជួរអាចអានបញ្ច្រាសគ្នាពីលើចុះក្រោម និងពីក្រោមឡើងលើ*

៨. *បន្ទះហូឡូក្រាមពណ៌ទឹកប្រាក់ មានទម្រង់ 2D/3D ពេលកាន់ក្រដាសប្រាក់ផ្ទៀងផ្ដងចុះឡើង មានបម្រែបម្រួលពណ៌និងរូបភាព ឆ្លាស់គ្នាច្រើនស្រទាប់និងច្រើនសណ្ឋាន*

៩. *ផ្នែកអទិស្សមាននៃបន្ទះហូឡូក្រាម មានចំណាំងពន្លឺក្រោមរស្មីពណ៌ស្វាយចេញជាពណ៌ចំរុះ*

១០. *បន្ទះពណ៌ប្រាក់ពីរកំណាត់នៅផ្នែកខាងខ្នងនៃធនប័ត្រ កាត់ពីលើផ្ទៃចតុកោណស្មើពីរផ្សេងគ្នាដែលមានសមាសធាតុជាប៉ូលីមើរ ។ នៅលើផ្ទៃជុំវិញនោះ រួមទាំងផ្ទៃនៃបន្ទះពណ៌ប្រាក់និងផ្ទៃចតុកោណស្មើផង សុទ្ធតែត្រូវបានបោះពុម្ពពីលើដោយអក្សរដ៏តូចល្អិត " NBC " ដោយប្រើបច្ចេកវិទ្យាអាំងតាគ្លីយ៉ូ*

១១. *បន្ទះពណ៌ប្រាក់ពីរកំណាត់ មានលក្ខណៈជាខ្សែសុវត្ថិភាពខ្នាតធំ មានលេខតូចល្អិត "១៥០០០" និង "15000" ឆ្លាស់គ្នាពីរជួរនៅពីលើនោះ ។ លេខទាំងពីរជួរនោះក៏មានការឆ្លាស់គ្នារវាងលេខផ្ងារដែលអាចអានបាននៅផ្នែកខាងមុខនៃធនប័ត្រ និងលេខផ្ដាប់ដែលអាចអានបាននៅផ្នែកខាងខ្នងនៃធនប័ត្រពេលឆ្លុះទៅរកប្រភពពន្លឺអ៊ីមួយ*

១២. *រូបព្រះសង្ហារនៃព្រះរាជាណាចក្រកម្ពុជាបោះពុម្ពដោយបច្ចេកវិទ្យាអាំងតាគ្លីយ៉ូ មានមួយផ្នែកតូចកាត់ពីលើបន្ទះហូឡូក្រាម ចេញជាពណ៌ផ្សេងគ្នា ដែលមានប្រសិទ្ធភាពប្រឆាំងការថតចម្លង*

១៣. *រូបនាគក្បាលប្រាំពីរ នៅជ្រាសាទអង្គរវត្ត រចនាដោយគំនូសបន្ទាត់ពិសេស និងបោះពុម្ពដោយបច្ចេកវិទ្យាអាំងតាគ្លីយ៉ូច្រើនពណ៌ គឺពីពណ៌ស្វាយទៅពណ៌ក្រម៉ៅ និងពីពណ៌ក្រម៉ៅទៅពណ៌ស្វាយវិញ*

១៤. *ព្រះធាយាល័ក្ខណ៍**ព្រះករុណា ព្រះបាទ សម្តេចព្រះបរមនាថ នរោត្តមសីហមុនី***
ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ទ្វាក់ពុម្ពដោយដៃតាមរបៀបប្រពៃណី និងបោះពុម្ពដោយបច្ចេកវិទ្យាអាំងតាគ្លីយ៉ូ ដែលមានលក្ខណៈត្រឹមខ្លាំង

១៥. *លេខ "១៥០០០" មានសាតពត្រឹមខ្លាំង*

១៦. *អក្សរ " NATIONAL BANK OF CAMBODIA " ដ៏តូចល្អិត មានគម្លាតតួអក្សរមិនស្មើគ្នា បោះពុម្ពដោយបច្ចេកវិទ្យាអាំងតាគ្លីយ៉ូ អាចមើលឃើញច្បាស់ដោយប្រើកែវពង្រីក*

១៧. *រូបក្បាច់លំអជាប្រពៃណីក្នុងព្រះបរមរាជវាំងនៅភ្នំពេញ គូសដោយគំនូសបន្ទាត់ពិសេសដោយឡែក បោះពុម្ពដោយបច្ចេកវិទ្យាអាំងតាគ្លីយ៉ូ និងមានពណ៌ឆ្លាស់គ្នា បូរពីពណ៌ត្នោតទៅពណ៌ខៀវ និងមានលក្ខណៈចំណាំងផ្ងារវាងជ្រុងផ្ទុយគ្នា*

១៨. *រូបភាពកំប៉ាំង " ១៥០០០ " អាចមើលឃើញច្បាស់ពេលកាន់ក្រដាសប្រាក់ផ្ទៀងផ្ដងបញ្ជិត ឬមួយពិនិត្យមើលដោយកែវពង្រីក*

១៩. *និមិត្តសញ្ញាសម្គាល់ប្រភេទប្រាក់សម្រាប់ជនពិការភ្នែក បោះពុម្ពកាត់ពីលើបន្ទះហូឡូក្រាម មានសភាពត្រឹមខ្លាំង*

២០. *គំនូសបន្ទាត់បង្កើតឡើងដោយលេខ "15000" ដ៏តូចល្អិតក្រោមទម្រង់វិជ្ជមាន លេខនីមួយៗមានកំរិតទេរមិនដូចគ្នា អាចមើលឃើញច្បាស់ដោយប្រើកែវពង្រីក*

២១. *អក្សរ " NBC " ដ៏តូចល្អិត ផ្ទុំឡើងជាគំនូសបន្ទាត់ មានសភាពប្រែប្រួលពីទម្រង់វិជ្ជមានទៅអវិជ្ជមាន អាចមើលឃើញច្បាស់ដោយប្រើកែវពង្រីក*

២២. *អក្សរ " NATIONAL BANK OF CAMBODIA " ដ៏តូចល្អិតមានទម្រង់ឯកភាពគ្នា ផ្ទុំឡើងជាគំនូសបន្ទាត់ និងបោះពុម្ពដោយបច្ចេកវិទ្យាអាំងតាគ្លីយ៉ូ*

២៣. *លេខ "១៥០០០" បោះពុម្ពដោយបច្ចេកវិទ្យាអាំងតាគ្លីយ៉ូច្រើនពណ៌ក្នុងស៊ុមព័ទ្ធជុំវិញ បូរពីពណ៌ស៊ីជំពូទៅខៀវ*

២៤. *រូបក្បាច់ចម្ងាក់នៅប្រាសាទបន្ទាយស្រី ប្រើគំនូសបន្ទាត់ពិសេសក្នុងការគូ និងបោះពុម្ពដោយអាំងតាគ្លីយ៉ូច្រើនពណ៌ បូរពីពណ៌ស្វាយទៅខៀវ*

២៥. *គំនូសបន្ទាត់សម្រាប់ផ្ទៀងផ្ងារ់ មានលក្ខណៈត្រឹមខ្លាំង បិតនៅជ្រុងក្រោមទាំងសង្ខាងនៃផ្នែកខាងមុខរបស់ធនប័ត្រ ក្នុងនោះគំនូសបន្ទាត់មួយផ្នែកតូចបោះពុម្ពកាត់ពីលើបន្ទះហូឡូក្រាមត្រង់ជ្រុងក្រោមខាងឆ្វេង*

២៦. *លេខ " 15000 " បោះពុម្ពដោយបច្ចេកវិទ្យាអាំងតាគ្លីយ៉ូមានពណ៌ចំរុះ*

២៧. *លេខ " 15000 " បោះពុម្ពដោយបច្ចេកវិទ្យាអាំងតាគ្លីយ៉ូមានពណ៌ផ្សេងគ្នា បូរពណ៌ពីខៀវទៅស៊ីជំពូ*

២៨. *ការបញ្ចូលគ្នាក្នុងផ្ទៃតែមួយនូវគំនូសបន្ទាត់ជាអក្សរនិងជាលេខដែលមានទំហំខុសគ្នា អាចមើលឃើញច្បាស់ដោយប្រើកែវពង្រីក*

២៩. *ផ្ទៃខាងក្រោយបោះពុម្ពដោយប្រើទឹកខ្មៅអុបសិតពិសេស មានចំណាំងពន្លឺក្រោមរស្មីពណ៌ស្វាយ ចេញជាពណ៌ក្រហមជាំ និងពណ៌ទឹកក្រូចចាស់*

៣០. *ការបោះពុម្ពផ្ទៃខាងក្រោយដោយប្រើទឹកខ្មៅមានធាតុលោហៈស្រមោលពណ៌ប្រាក់មានចំណាំងពន្លឺក្រោមរស្មីពណ៌ស្វាយ ចេញជាពណ៌លឿង*

៣១. *ការបោះពុម្ពអុបសិតនូវក្បាច់លំអផ្ទៃខាងក្រោយជាមួយគំនូសបន្ទាត់ពិសេស មានចំណាំងពន្លឺក្រោមរស្មីពណ៌ស្វាយ ចេញជាពណ៌ទឹកក្រូច*

៣២. *រូបរិមានឈ្នះឈ្នះ រចនាដោយគំនូសបន្ទាត់ពិសេសដោយឡែក និងបោះពុម្ពដោយបច្ចេកវិទ្យាអាំងតាគ្លីយ៉ូច្រើនពណ៌ បូរពណ៌ពីស៊ីជំពូទៅខៀវ*

៣៣. *រូបចម្លាក់ថ្ម ដំរីក្បាលបីមានស្ងាប-ត្រុឌ-ហង្ស នៅជ្រុងទាំងបួននៃខៀវរិមានឈ្នះឈ្នះគូសដោយគំនូសបន្ទាត់ពិសេស និងបោះពុម្ពដោយបច្ចេកវិទ្យាអាំងតាគ្លីយ៉ូចំរុះពណ៌ បូរពណ៌ពីស៊ីជំពូទៅពណ៌ត្នោតនិងពណ៌ខៀវ*

៣៤. *គំនូសបន្ទាត់ផ្ទុំឡើងដោយលេខដ៏តូចល្អិតក្នុងទម្រង់វិជ្ជមាន បោះពុម្ពដោយអុបសិត*

៣៥. *គំនូសបន្ទាត់ផ្ទុំឡើងដោយអក្សរដ៏តូចល្អិតក្នុងទម្រង់អវិជ្ជមាន បោះពុម្ពដោយអាំងតាគ្លីយ៉ូ*

៣៦. *ផ្នែបដិបក្ខការថតចម្ងង់ បង្កើតឡើងដោយគំនូសបន្ទាត់ខ្មារៗ មានកម្រាស់ខុសគ្នា*

៣៧. *ផ្នែលំអជាលេខផុស " ១៥០០០ " ផ្ទុំឡើងដោយគំនូសបន្ទាត់ដ៏តូចខ្មារ*

៣៨. *រូបភាពលំអជាលេខផុស " 15000 " ព្រាលៗ គូសដោយគំនូសបន្ទាត់ពិសេសដ៏តូចល្អិតដែលមានទំហំខុសគ្នា*

៣៩. *រូបក្បាច់លំអជាប្រពៃណីក្នុងព្រះបរមរាជវាំងនៅភ្នំពេញ បង្កើតឡើងដោយគំនូសបន្ទាត់ពិសេសគ្មានសណ្តាប់ធ្នាប់ បោះពុម្ពដោយអុបសិត*

៤០. *ព្រះធាយាល័ក្ខណ៍**ព្រះករុណា ព្រះបាទ សម្តេចព្រះបរមនាថ នរោត្តមសីហមុនី*** *ព្រម ជាមួយព្រះវររាជបិតា និងព្រះវររាជមាតា ក្នុងព្រះរាជពិធីស្រោចស្រពព្រះសុគន្ធារីរៀបចំរូបភាពដោយគំនូសបន្ទាត់ឯកភាពជាប្រពៃណី បោះពុម្ពដោយបច្ចេកវិទ្យាអុបសិត*

៤១. *អក្សរ " NBC " ដ៏តូចល្អិត បោះពុម្ពដោយអាំងតាគ្លីយ៉ូចំរុះពណ៌ មានកម្រាស់បន្ទាត់ខុសៗគ្នា*

៤២. *ផ្នែបដិបក្ខការថតចម្ងង់ បង្កើតឡើងដោយគំនូសបន្ទាត់ខ្មារៗ មានកម្រាស់ស្មើៗគ្នា*

៤៣. *រូបភាពអទិស្សមាន ជារូបព្រះសង្ហារនៃព្រះរាជាណាចក្រកម្ពុជា និងលេខ " ១៥០០០ " មានចំណាំងពន្លឺក្រោមរស្មីពណ៌ស្វាយ ចេញជាពណ៌លឿង*

៤៤. *រូបភាពអង្គដោចំណាំ មើលពីផ្នែខាងមុខ មានគំនូសបន្ទាត់ស៊ីគ្នាទាំងស្រុងរវាងផ្នែខាងមុខនិងផ្នែខាងខ្នងនៃធនប័ត្រ*

៤៥. *រូបភាពអង្គដោចំណាំ មើលពីផ្នែខាងខ្នង មានគំនូសបន្ទាត់ស៊ីគ្នាទាំងស្រុងរវាងផ្នែទាំងសង្ខាងនៃធនប័ត្រ*

៤៦. *រូបភាពអង្គដោចំណាំ មើលពីផ្នែខាងមុខ ពេលលើកធនប័ត្រមើលឆ្លុះពីមុខពន្លឺអ៊ីមួយ*

៤៧. *រូបភាពអង្គដោចំណាំ មើលពីផ្នែខាងមុខក្រោមរស្មីពណ៌ស្វាយ ចេញជាពណ៌ក្រហមជាំ និងពណ៌លឿង*

៤៨. *រូបភាពអង្គដោចំណាំ មើលពីផ្នែខាងខ្នងក្រោមរស្មីពណ៌ស្វាយ ចេញជាពណ៌ក្រហមជាំ និងពណ៌ស្វាយ*

៤៩. *លេខមាលាបោះពុម្ពដោយទឹកខ្មៅពណ៌ផ្សេងគ្នា ក្នុងនោះមាលានិងលេខ " 15 " បោះពុម្ពដោយទឹកខ្មៅពណ៌ក្រហម និងលេខផ្សេងពីនោះបោះពុម្ពដោយទឹកខ្មៅពិសេសពណ៌ខ្មៅ មានធាតុធក់*

៥០. *លេខមាលាចំណែកពណ៌ក្រហម មានចំណាំងពន្លឺក្រោមរស្មីពណ៌ស្វាយ ចេញជាពណ៌ទឹកក្រូច រីឯលេខមាលាចំណែកពណ៌ខ្មៅ មានចំណាំងពន្លឺក្រោមរស្មីពណ៌ស្វាយចេញជាពណ៌លឿង*

៥១. *លេខ " មួយម៉ឺនប្រាំពាន់រៀល " បោះពុម្ពដោយអាំងតាគ្លីយ៉ូបួនពណ៌ ក្រម៉ៅ ស៊ីជំពូ ខៀវ និងខ្មៅ*

៥២. *លេខ " មួយម៉ឺនប្រាំពាន់រៀល " បោះពុម្ពដោយអាំងតាគ្លីយ៉ូបីពណ៌ ក្រម៉ៅ ស៊ីជំពូ និងខ្មៅ*